ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កិច្ចប្រជុំតាមកម្មវិធី BlueJeans
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី**

នាព្រឹកថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០។ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំវីដេអូ ខនហ្វឺរេន តាមកម្មវិធី BlueJeans ដែលមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាអនុប្រធាន ខុទ្ទកាល័យ អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន សរុបចំនួន២៨រូប ដើម្បីពិនិត្យលទ្ធផលសកម្មភាពរបស់ថ្នាក់ដឹកនាំ និងជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រីបានមានប្រសាសន៍ស្វាគមន៍ និងបានថ្លែងកោតសរសើរមន្ត្រីរាជការទាំងអស់ដែលបានធ្វើការយ៉ាងសកម្ម និងបានទទួលនូវលទ្ធផលល្អ។ ជាមួយគ្នានោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានណែនាំថា ត្រូវបន្តប្រឹងប្រែងទាំងអស់គ្នា ដើម្បីការកែចម្រើនរបស់ស្ថាប័ន និងទទួលបានជំនឿទុកចិត្តពីថ្នាក់ដឹកនាំ។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រីបានអនុញ្ញាតជូនឯកឧត្តម **ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការ ធ្វើបទបង្ហាញស្តីអំពីរបាយការណ៍វឌ្ឍនភាពនៃលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយបង្ហាញពីភាពប្រសើរ និងបញ្ហាប្រឈម ប្រចាំខែមីនា ឆ្នាំ២០២០ និងលើកទិសដៅសម្រាប់ខែបន្ទាប់។

បន្ទាប់ពីស្តាប់របាយការណ៍ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើការណែនាំដល់ថ្នាក់ដឹកនាំទាំងអស់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ថា ក្នុងស្ថានភាពនៃការរីករាលដាលមេរោគកូវីដ១៩នេះ យើងអាចបន្តដំណើរការប្រជុំបាន និងតាមដានការងារបានតាមវីដេអូខនហ្វឺរេន។ ដូច្នេះ បើសិនជាចង់រៀបចំកិច្ចប្រជុំ ដូចជាកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស អាចទាក់ទងជាមួយឯកឧត្តម **ស៊ន ពិសិដ្ឋ** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីប្រជុំតាម BlueJeans ជូន។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្ត ដោយណែនាំឱ្យឯកឧត្តមអនុប្រធាន **ឆា ផល** និងឯកឧត្តមអនុប្រធាន **រស់ សីលវ៉ាត់** ត្រួតពិនិត្យឡើងវិញលើផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ សម្រាប់ការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ និងថវិកាបដិកាគរបស់រាជរដ្ឋាភិបាល នៅឆ្នាំ២០២១ ដែលគ្រោងថវិកាចំនួន ២លានដុល្លារ ឆ្នាំ២០២២ ចំនួន២.៥ លានដុល្លារ និងឆ្នាំ២០២៣ ចំនួន៥លានដុល្លារ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រីបានអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវ អនុប្រធានមានមតិយោបល់ក្នុងនោះមាន៖

១- ឯកឧត្តមអនុប្រធាន **ឆា ផល** បានលើកឡើងអំពីវឌ្ឍនភាពនៃលិខិតជូនដំណឹងលេខ២១៣ ស.ជ.ណ ដែលក្នុងនោះ ឯកឧត្តមសាស្ត្រាចារ្យ **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល បានឯកភាពជាផ្លូវការក្នុងការអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅតាមមណ្ឌលសុខភាព ដោយផ្អែកលើ ភាពជាអ្នកដឹកនាំ (Leadership) ភាពជាដៃគូ (Partnership) និងការវិនិយោគ (Investment)។ ចំពោះភាពជាដៃគូ (Partnership) របស់អង្គការក្រៅរដ្ឋាភិបាល (NGO) មិនទាន់អនុវត្តការងារបានល្អជាមួយមន្ត្រីរដ្ឋាភិបាលទេ ដូចជាគណៈកម្មាធិការអេដស៍តាមមណ្ឌលសុខភាព តាមឃុំឬសង្កាត់។

២- ឯកឧត្តមអនុប្រធាន **ជា ច័ន** បានផ្តល់ជាព័ត៌មានថា បច្ចុប្បន្ននេះ នៅប្រទេសកូរ៉េគេបានយកផ្លាស្មាពីអ្នកជាសះស្បើយពីជំងឺកូវីដ១៩ ទៅចាក់លើអ្នកដែលកើតជំងឺកូវីដ១៩ដែលមានសភាពធ្ងន់ខ្លាំង និងបានបង្ហាញថាបានជួយបន្ថយសភាពជំងឺធ្ងន់បាន។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានរំឭកថា ចំពោះជំងឺកូវីដ១៩ គឺមានភាពស្មុគស្មាញណាស់ និងកាន់តែធ្ងន់ធ្ងរមានទ្រង់ទ្រាយធំដែលវាអាចជាហានិភ័យខ្ពស់ក្នុងការឆ្លង ដែលកំពុងបន្តសម្លាប់មនុស្សរាប់ពាន់នាក់ជារៀងរាល់ថ្ងៃ។ រហូតមកទល់ពេលនេះកម្ពុជាមិនទាន់មានការចម្លងជំងឺកូវីដ១៩នៅក្នុងសហគមន៍នៅឡើយទេ។ ករណីកូវីដ១៩ ថ្មីមានភាគច្រើនជាករណីនាំចូល ហើយក៏មិនទាន់មានប្រជាពលរដ្ឋកម្ពុជាណាម្នាក់ស្លាប់ ដែលបង្កដោយជំងឺកូវីដ១៩ដែរ។ ជំងឺកូវីដ១៩ វាអាចនឹងបង្កឱ្យមានភាពមហន្តរាយដល់អាយុជីវិត និងធ្វើឱ្យខាតបង់ធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច។ ដូច្នេះដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងការពារខ្លួនយើងពីការឆ្លងជំងឺកូវីដ១៩ យើងទាំងអស់ត្រូវគោរព និងអនុវត្តតាមបទបញ្ជា និងវិធានការទាំងឡាយដែលរាជរដ្ឋាភិបាលបានដាក់ជូនឱ្យបានល្អ ដូចជា ការរក្សាគម្លាតពីគ្នា ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ លាងសម្អាតដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ ជាមួយអាកុល ឬដែលសម្លាប់មេរោគ មិនត្រូវធ្វើដំណើរដោយសេរីឬជួបជុំគ្នាឡើយ។

ជំងឺកូវីដ១៩ កំពុងរាតត្បាតជាសកល (Pandemic) ដែលបណ្តាលឱ្យប្រទេសមានផលប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ និងបានគំរាមកំហែងដល់អាយុជីវិត។ យើងត្រូវបន្ថយការចុះបេសកកម្ម បង្វែរមកធ្វើការងារតាមផ្ទះជាពិសេសអ្នកដែលមានវ័យចំណាស់អាយុពី៦០ឆ្នាំឡើង ដើម្បីរៀបចំថវិកា ឃុំ/សង្កាត់ និងត្រៀមអនុវត្តការងារឱ្យបានត្រឹមត្រូវ មានគុណភាព និងទទួលបានបរិមាណច្រើន។

លើសពីនេះទៅទៀត ឯកឧត្តមទេសរដ្ឋមន្ត្រីបានផ្តល់អនុសាសន៍ណែនាំដូចខាងក្រោម ៖

១- ឯកឧត្តម **ឆា ផល** និងឯកឧត្តម**រស់ សីលវ៉ាត់** ត្រូវរៀបចំសេចក្តីព្រាងសកម្មភាព និងថវិកា សម្រាប់ថ្នាក់ឃុំ/សង្កាត់ រៀបចំកិច្ចប្រជុំអន្តរក្រសួង ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តស.ជ.ណ២១៣ និងសិក្សា

ស្វែងយល់អំពីស្ថានភាពប្រយុទ្ធនឹងជំងឺអេដស៍ជាពហុវិស័យនៅថ្នាក់ក្រោមជាតិ តាមរយៈការដាក់បញ្ចូលការងារប្រយុទ្ធនឹងជំងឺអេដស៍ក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ និងពិនិត្យឡើងវិញលើអ្នកផ្ទុកមេរោគអេដស៍ដឹងស្ថានភាពផ្ទុកមេរោគអេដស៍ អ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យ និងអ្នកផ្ទុកមេរោគអេដស៍ ដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

២- ឯកឧត្តមទេសរដ្ឋមន្ត្រី បានណែនាំ ជាពិសេសដល់ឯកឧត្តម អនុប្រធាន **តែង គន្ធី** ឱ្យជួយពិនិត្យផ្ទៀងផ្ទាត់ខ្លឹមសារនៃគោលការណ៍ណែនាំជាតិស្តីពីការបង្ការ ការចម្លងមេរោគអេដស៍ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាល ដែលក្រុមការងារបច្ចេកទេសយើងបានធ្វើរួចហើយ បន្ទាប់មករៀបចំតាក់តែងជាសេចក្តីសម្រេចមួយអំពីគោលការណ៍ណែនាំនេះ ដោយរួមបញ្ចូលទាំងគោលការណ៍ណែនាំខាងវិស័យសុខាភិបាលដែលក្រសួងសុខាភិបាលបានចេញឱ្យប្រើប្រាស់ មកជាគោលការណ៍ណែនាំជាតិ ដែលមានទាំងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៣- ឯកឧត្តម **ហោ ឃុនឡេង** ត្រួតពិនិត្យលើការងារវីដេអូផ្សព្វផ្សាយអប់រំស្តីអំពីមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានសមស្របតាមបច្ចេកទេស ដោយផ្តល់អនុសាសន៍ក្នុងការកែតម្រូវ មុនផ្សព្វផ្សាយជាផ្លូវការ។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រីបានណែនាំឯកឧត្តមអគ្គលេខាធិការ ឱ្យ ១) រៀបចំគម្រោងបង្រៀន ដើម្បីពង្រឹងសមត្ថភាពមន្ត្រី តាមរយៈការបើកវគ្គបណ្តុះបណ្តាល ២) រៀបចំផែនការថវិកា និង៣) រៀបចំសន្ធានុក្រមដោយធ្វើការពន្យល់ពាក្យ ជាពិសេសអក្សរកាត់ ធ្វើការបកប្រែឱ្យបានត្រឹមត្រូវ ដោយរៀបចំក្រុមការងារជជែកពិភាក្សាគ្នា ហើយដាក់ឆ្លងក្រុមប្រឹក្សាជាតិភាសាខ្មែរ។ លើសពីនេះទៅទៀត សូមកុំឱ្យមានការជួបជុំគ្នានៅផ្លូវចូលឆ្នាំខ្មែរនេះ យើងគ្រាន់តែជូនពរគ្នាតាមតេឡេក្រាមបានហើយ។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាដែលមានវត្តមានក្នុងកិច្ចប្រជុំ ឱ្យមានសុខភាពល្អបរិបូណ៌ និងជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

នាយកខុទ្ទកាល័យ

ស៊ុត_ថងជាន់


BlueJeans | DOLBY VOICE
Piseth's Meeting - ID: 670 941 5168
Help
Piseth Sorn is talking


BlueJeans | DOLBY VOICE
Piseth's Meeting - ID: 670 941 5168
Help
Chanravuth Ly
សូមអរគុណ!
Say bunna
Sophay
Kong Rotha
Dr. Kok Vanna joined Telegram

phalla.tia is talking
Dr. Kok Vanna joined Telegram